**BMI0178**

## សម្ភាសន៍ជាមួយឈ្មោះ ជឹង សួប ភេទស្រី អាយុ៥០ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ កងកុមារ

## រស់នៅភូមិប៉ោយតាប៉ែន ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

## ០០:២៩:១៥

## ១៦ទំព័រ

ដារ៉ា ៖ ជំរាបសួរខ្ញុំចង់ស្គាល់ឈ្មោះពេញមីង មីងឈ្មោះអីដែរ?

សួប ៖ ខ្ញុំឈ្មោះ ជឹង សួប ។

ដារ៉ា ៖ ជឹង សួប?

សួប ៖ ចា៎

ដារ៉ា ៖ មីងមានអាយុប៉ុន្មានឆ្នាំហើយ?

សួប ៖ ៥០គត់ហើយ ។

ដារ៉ា ៖ មីងកើតនៅក្នុងឆ្នាំណា?

សួប ៖ កើតឆ្នាំប៉ុន្មានទេ ៧៩អ្ហី ។

ដារ៉ា ៖ ទេកើតអ្ហាស មីងកើតនៅឆ្នាំណា? កើតឆ្នាំខ្មែរត្រូវឆ្នាំអី?

សួប ៖ កើតឆ្នាំខាលខ្ញុំនោះ ។

ដារ៉ា ៖ អ្ហោ! កើតឆ្នាំខាល?

សួប ៖ ចា៎ ។

ដារ៉ា ៖ មីងកើតនៅភូមិណា?

សួប ៖ កើតភូមិនេះឯង ភូមិកំនើតភូមិតាប៉ែន ។

ដារ៉ា ៖ អញ្ជឹង! ស្រុកកំនើតរបស់មីងម៉ង?

សួប ៖ ចា៎

ដារ៉ា ៖ ហើយសព្វថ្ងៃនេះគឺនៅភូមិតាប៉ែនហ្នឹង?

សួប ៖ សព្វថ្ងៃនៅភូមិតាប៉ែនហ្នឹងឯង ។

ដារ៉ា ៖ ហើយមីងមានគ្រួសារមីងឈ្មោះអីដែរ?

សួប ៖ ទេខ្ញុំមេម៉ាយ ។

ដារ៉ា ៖ មេម៉ាយ គ្រួសារមីងឈ្មោះអីមុន?

សួប ៖ ឈ្មោះ ទុយ ។

ដារ៉ា ៖ គាត់ម៉េច?

សួប ៖ គាត់ឈឺៗស្លាប់ ។

ដារ៉ា ៖ គាត់ស្លាប់ដោយសារជម្ងឺទេណោះ?

សួប ៖ ចា៎

ដារ៉ា ៖ ស្លាប់យូរហើយមីងណោះ?

សួប ៖ ស្លាប់ពីអាយុ៣៤ ខ្ញុំ៣០គត់ ។

ដារ៉ា ៖ អ៊ោ! តាំងពីមីងអាយុ៣០ម៉េះមីងណោះ?

សួប ៖ ចា៎

ដារ៉ា ៖ ២០ឆ្នាំហើយ ។ អញ្ចឹងស្លាប់ក្រោយប៉ុល ពតទេណោះ?

សួប ៖ ក្រោយ កាលស្របក់ប៉ុល ពតខ្ញុំនៅតូច ។

ដារ៉ា ៖ ចឹងមីងមានកូនចៅប៉ុន្មាននាក់?

សួប ៖ មាន៥នាក់ ។

ដារ៉ា ៖ ស្រីប៉ុន្មានប្រុសប៉ុន្មានមីង?

សួប ៖ ស្រី៣ ប្រុស២ ។

ដារ៉ា ៖ ឥឡូវធំៗអស់ហើយមីង?

សួប ៖ ធំហើយ ។

ដារ៉ា ៖ មានគ្រួសារមានអីខ្លះនៅ?

សួប ៖ ចា៎ នៅលីវពីរ ។

ដារ៉ា ៖ នៅលីវពីរ មានគ្រួសារ៣នាក់ហើយ?

សួប ៖ ចា៎ លីវ២ នៅលីវ៣ ។

ដារ៉ា ៖ លីវ៣អ្ហេះ?

សួប ៖ ចា៎

ដារ៉ា ៖ ហើយមីងមានបងប្អូនប៉ុន្មាននាក់ បងប្អូនបង្កើត?

សួប ៖ បងប្អូន៤នាក់ ៥នាក់ទាំងខ្ញុំ ។

ដារ៉ា ៖ ហើយមីងជាកូនទីប៉ុន្មាន?

សួប ៖ កូនទី៥ ។

ដារ៉ា ៖ អ៊ោ! ចុងក្រោយគេមីង?

សួប ៖ ទេពៅ មានប្អូនពីរនាក់ទៀត ។

ដារ៉ា ៖ ចឹងមីងជាកូនទី៣?

សួប ៖ ចា៎

ដារ៉ា ៖ ឪពុកមីងឈ្មោះអីគេ?

សួប ៖ ឈ្មោះ ញ៉យ ។

ដារ៉ា ៖ ឪពុកមីង?

សួប ៖ ឈ្មោះ ញ៉យ ។

ដារ៉ា ៖ ស្អី ញ៉យ?

សួប ៖ ខ្ញុំអត់ស្គាល់ទេជីតាឪ ។

ដារ៉ា ៖ ដឹងតែ ញ៉យ ចឹង?

សួប ៖ ចា៎

ដារ៉ា ៖ ហើយគាត់នៅរស់ទេមីង?

សួប ៖ ស្លាប់អស់ ។

ដារ៉ា ៖ ស្លាប់ជំនាន់ណាមីង?

សួប ៖ ស្លាប់សម័យអាពត ។

ដារ៉ា ៖ ស្លាប់ដោយសារអីមីង?

សួប ៖ គាត់ឈឺ ដាច់បាយគាត់ឈឺ ។

ដារ៉ា ៖ ដោយសារឈឺដាច់បាយ?

សួប ៖ ចា៎

ដារ៉ា ៖ ចុះម្ដាយមីង?

សួប ៖ ម្ដាយស្លាប់កាលពីប៉ុន្មានឆ្នាំនេះឯង ។

ដារ៉ា ៖ គាត់ឈ្មោះអី?

សួប ៖ ឈ្មោះ នួន ។

ដារ៉ា ៖ មីងបានរៀនបានសូត្រទេពីមុនម៉ោ?

សួប ៖ ខ្ញុំរៀនតិច ។

ដារ៉ា ៖ រៀនតិចទេណោះ ។ រៀនបានប៉ុន្មានឆ្នាំដែរ?

សួប ៖ រៀនបាន មុនគេហៅថ្នាក់ទី១០ សព្វថ្ងៃហៅថ្នាក់ទី៣ ។

ដារ៉ា ៖ រៀនបានថ្នាក់ទី១០?

សួប ៖ ចាំ

ដារ៉ា ៖ ថ្នាក់ទី១០ហ្នឹងចឹងរៀនបាន២ឆ្នាំណោះ?

សួប ៖ ចាំ រៀនបាន៣ឆ្នាំលោកគ្រូ សម័យមុនហៅថ្នាក់ទី១០ សព្វថ្ងៃហៅថ្នាក់ទី៣ ។

ដារ៉ា ៖ ហើយរៀន ហេតុម៉េចបានអត់បានរៀនបន្តទៀត?

សួប ៖ ខ្ញុំអត់ពេករកស៊ីច្រូតស្រូវរកស៊ីចិញ្ចឹមម៉ែ ប្អូន ។

ដារ៉ា ៖ កាលហ្នុងអាយុប៉ុន្មានហើយកាលហ្នុង?

សួប ៖ កាលហ្នុងអាយុ១២-១៣ ។

ដារ៉ា ៖ ចឹងពេល ៗ ខ្មែរក្រហមចូល ជំនាន់ពេលប៉ុល ពតចូលមកកាន់កាប់ភូមិមីងហ្នឹង ក្នុងឆ្នាំ៧៥កាលហ្នឹងមីងអាយុប៉ុន្មានហើយ?

សួប ៖ កាលហ្នុងអាយុ១៨ហ្នឹងឯង យកពួកខ្ញុំទៅលើកដីទៅចល័តបែកពីម៉ែ ។

ដារ៉ា ៖ ចឹងក្នុងក្រុមគ្រួសារមីងមានការផ្លាស់ប្តូរឬក៏ជម្លៀសទៅនៅណាអីផ្សេងទៀតទេ?

សួប ៖ ជម្លៀសទៅនៅប៉ោយសំរ៉ោង ។

ដារ៉ា ៖ អញ្ចឹងនៅក្នុងអ្នកភូមិតាប៉ែននេះទៅនៅភូមិប៉ោយសំរ៉ោងទាំងអស់?

សួប ៖ ចាំ

ដារ៉ា ៖ ចឹងពេលហ្នឹងមីងបាននៅជាមួយឪពុកម្តាយមីងទេ?

សួប ៖ អត់បាននៅទេ បែករហូត ។

ដារ៉ា ៖ បែកជំបូងបង្អស់មីងបែកទៅនៅក្រុមណា កងណា?

សួប ៖ នៅកងអ៊ំ ខៀន នេះឯង ប៉ុនឥឡូវគាត់ស្លាប់ហើយទាំងប្តីទាំងប្រពន្ធគាត់ ។

ដារ៉ា ៖ កង ខៀន ខៀន ហ្នឹងស្រីឬប្រុស?

សួប ៖ ស្រី ។

ដារ៉ា ៖ គាត់ជាប្រធានកងមីង?

សួប ៖ ចាំ

ដារ៉ា ៖ កងកុមារឬកងនារី?

សួប ៖ កងកុមារៗ កងពួកខ្ញុំនឹងឯង ។

ដារ៉ា ៖ កាលហ្នឹងមីងនៅកងកុមារទេ?

សួប ៖ ចា៎ៗ នៅតូច ។

ដារ៉ា ៖ ហើយប្រធានកងមីងឈ្មោះ ខៀន?

សួប ៖ ចា៎

ដារ៉ា ៖ កងកុមារមីងដឹបូងគេឲ្យធ្វើអី ហើយនៅណា?

សួប ៖ មុនដំបូងនៅស្វាយភ្នំបាក់កងវ៉ា ។

ដារ៉ា ៖ ភ្នំបាក់កងវ៉ា?

សួប ៖ ចា៎

ដារ៉ា ៖ កងវ៉ាហ្នឹងភូមិអ្ហែះ?

សួប ៖ ភូមិគេៗ ភូមិកងវ៉ា ប៉ុននៅកន្លែងព្រៃពួកខ្ញុំណោះដាំពោត កាច់ពោត ។

ដារ៉ា ៖ កាច់ពោត?

សួប ៖ ចា៎ ម៉ោពីកងវ៉ាវិញនេះ លើកទំនប់ស្រែះ ចាប់ពីប៉ោយសំរោងទៅស្រែកំបោរ ។

ដារ៉ា ៖ លើកទំនប់នៅស្រែះបឹងមីងអ្ហែះ?

សួប ៖ ចា៎ៗ វាលកំបោរ ។

ដារ៉ា ៖ ស្រែះវាលកំបោរៗ ស្មានមើលបានប៉ុន្មានខែប៉ុន្មានឆ្នាំទៅលើកទំនប់នៅហ្នឹងមីង?

សួប ៖ យូរកាលនោះលោកគ្រូ ប៉ុនខ្ញុំអត់ដឹងខែដឹងអីទេ ប៉ុនដឹងថាយូរ រួចម៉ាកន្លែងៗ ទៅផ្លាស់ម៉ាកន្លែង ។

ដារ៉ា ៖ អញ្ចឹងបានន័យថាវាចល័តរហូត?

សួប ៖ ចា៎ ចល័តរហូត រួចកំបោរទៅ ទៅអាងត្រពាំងថ្ម ។

ដារ៉ា ៖ មុនទៅដល់អាងត្រពាំងថ្មហ្នឹងមីងនៅក្រុមយាយ ខៀន ដដែល?

សួប ៖ ចា៎ នៅយាយ ខៀន ។

ដារ៉ា ៖ ហើយអ្នកណាជាអ្នកគ្រប់គ្រងរួម?

សួប ៖ ចា៎ៗ រួម ឈ្មោះ យាយ ខៀន នៅប្រធានតែកុមារទេ ប្រធានតែពួកខ្ញុំទេ ប្រធានយុវជនផ្សេង ។

ដារ៉ា ៖ ហើយអ្នកណាគេអ្នកគ្រប់គ្រងពីលើធំទៀតពីណាគេ?

សួប ៖ គាវ៉ាល់នឹងឯង ។

ដារ៉ា : តាវ៉ាល់?

សួប : ចា៎ គេវ៉ៃងាប់អស់ហើយ ។

ដារ៉ា : មីងថាមានតាវ៉ាល់ ពីណាគេទៀត?

សួប : តាវ៉ាល់ តាមង ។

ដារ៉ា : តាមង?

សួប : តាសនៗ ដែលគេវ៉ៃ ៣នាក់ ។

ដារ៉ា : អញ្ចឹងគ្រប់គ្រងនៅហ្នឹង មីងកងកុមារៗ គេហៅកងកុមារតំបន់ឬក៏ភូមិភាគកាលហ្នឹង?

សួប : តំបន់ដើរចល័តកន្លែងធំៗ យកទៅដាក់ត្រង់ណា ដូចថាត្រង់ណាយកទៅដាក់ត្រង់ហ្នុង ។

ដារ៉ា : អញ្ចឹងចល័តរហូត?

សួប : ចា៎ រហូត ។

ដារ៉ា : ពេលធ្វើលើកទំនប់លើអីនៅស្រែះហើយមីងត្រូវបានបញ្ជូនទៅណាទៀត?

សួប : ស្រែះហើយទៅអាងត្រពាំងថ្ម ត្រពាំថ្មរួចហើយទៅវាលត្រគៀបក្តាម ។

ដារ៉ា : ចឹងខ្ញុំចង់សួរលម្អិតបន្តិចទាក់ទងទៅនឹងអាងត្រពាំងថ្មមីង មីងទៅដល់ហ្នឹងម៉ាកងមីងនៅហ្នឹង ដដែល ម៉ាកងដែលដឹកនាំដោយ ខៀន នេះ?

សួប : ចា៎ៗ

ដារ៉ា : ហើយមីងនៅអាងត្រពាំងថ្មមីងលើកនៅម្តុំណា?

សួប : លើកនៅចុងភូមិប៉ោយតាអុង ។

ដារ៉ា : អរ! អាកន្លែងហ្នឹងនៅក្នុងភូមិប៉ោយតាអុង?

សួប : ចា៎ ចុងភូមិគេ វាល ។

ដារ៉ា : អាហ្នឹងបើនិយាយពីទំនប់ហ្នឹងនៅក្នុងហ្នឹងមាន នៅកំណាត់ម្តុំណា? នៅស្ពានទី១ ទី២ ទី៣ មីង?

សួប : ស្ពានម៉ាកំណាត់ ខ្ញុំលើកម៉ាចប់ហ្នឹងឯងលោកគ្រូ ដំបូងគេស្ពានទី១ ស្ពានទី២ ស្ពានទី៣ រហូតដល់ចប់ម៉ោភូមិគេអីណោះស្វាយស ។

ដារ៉ា : ដល់កន្លែងភូមិ?

សួប : ភូមិស្វាយសគេណោះ ម៉ាៗវង់ ។

ដារ៉ា : អ្នកណាគេអ្នកគ្រប់គ្រងនៅអាងត្រពាំងថ្មហ្នឹងធំជាងគេ?

សួប : មានតែតាវ៉ាល់នេះឯង ដល់នីរតីគេចូលម៉ោទៅនីរតីគេវ៉ៃគាត់ចោល នីរតីគេគ្រប់គ្រងម្តង ។

ដារ៉ា ៖ អញ្ចឹងអ្ហេះ?

សួប ៖ ចា៎

ដារ៉ា ៖ ចុះតាមោងហើយតាសនគាត់បានទៅគ្រប់គ្រងនៅហ្នុងទេ?

សួប ៖ ទៅអាងត្រពាំងថ្មដែរ ។

ដារ៉ា ៖ ទៅហ្នុងដែរ?

សួប ៖ ចា៎ ទៅទាល់តែចប់ពួកនីរតីចូលម៉ោបានគេវៃពួកគាត់ទៅគេកាន់ក្តាប់ម្តង ។

ដារ៉ា ៖ ចឹងពេលមីងទៅលើកនៅអាត្រពាំងថ្មហ្នឹងការងារគេដាក់ផែនការឲ្យមីងយ៉ាងម៉េចទៅ?

សួប ៖ ក្នុងម៉ាថ្ងៃ២ម៉ែត្រគីបកន្លះ។ យប់២ម៉ែត្រគីបកន្លះ ។

ដារ៉ា ៖ ចុះម៉ាថ្ងៃហ្នឹង៥ម៉ែត្រគីបចឹង?

សួប ៖ ចា៎ ៥ម៉ែត្រទាំងយប់ទាំងថ្ងៃ ។

ដារ៉ា ៖ ពេលមីងទៅដល់ភ្លាមគេកម្រិតប៉ុនហ្នឹងម៉ង?

សួប ៖ ចា៎ ទៅដល់ភ្លាគេវាស់ដីឲ្យ កំណត់ម៉ាថ្ងៃ២ម៉ែត្រគីប។ ។

ដារ៉ា ៖ ២ម៉ែត្រគីបកន្លះឬ២ម៉ែត្រគីប?

សួប ៖ អរ! ២ម៉ែត្រគីបកន្លះ ។ ខ្ពស់ណាស់លោកគ្រូអើយដាក់ជណ្តើរឡើង ។

ដារ៉ា ៖ កម្ពស់ណាមីង បើស្នានជាស្នានកម្ពស់ប្រហែលជាប៉ុន្មានទៅ?

សួប ៖ កម្ពស់៣ម៉ែត្រ ៣ម៉ែត្រកន្លះ ដល់ស្រុតទៅសព្វថ្ងៃនៅប៉ុន្មានទេ ។

ដារ៉ា ៖ ចុះទទឹងវាប៉ុន្មាន?

សួប ៖ ទទឹងវាប៉ុន្មានទេលោកគ្រូធំគ្រាន់ ប្រហែលជា៥ម៉ែត្រដឹងលោកគ្រូ ។

ដារ៉ា ៖ ចឹងម៉ារយៈពេលដែលមីងនៅកន្លែងត្រពាំងថ្មហ្នឹងគឺលើកកម្រិត២ម៉ែត្រកន្លះរហូត?

សួប ៖ ចា៎ ២ម៉ែត្រកន្លះរហូត ។

ដារ៉ា ៖ ២ម៉ែត្រកន្លះរហូត ចឹងហើយមីងនៅហ្នឹងម៉ារយៈលើកទាល់តែហើយម៉ង?

សួប ៖ ចា៎ ទាល់តែហើយទៅម៉ាកន្លែងទៀត បើមិនរួចគេអត់ឲ្យចេញទេ ទៅដល់កន្លែងណាដូចកន្លែងណាចឹង ។

ដារ៉ា ៖ ចុះមីងទៅដល់ដំបូងហ្នឹងទំនប់ត្រពាំងថ្មហ្នឹងមានគេលើកហើយនៅ?

សួប ៖ ទេវាលស្រែទេលោកគ្រូ វាលស្រែ ចាប់ផ្តើមដុបអីណោះ ចាប់ផ្តើម កាលណោះលើកវង់ព័ទ្ធស្នែងក្របីលោកគ្រូ ។

ដារ៉ា ៖ អញ្ចឹងពេលមីងទៅលើកដំបូងហ្នឹងអត់ទាន់មានជាទំនប់ជាអាងអីទេ?

សួប : អត់ទាន់ទេមានអាងទេលោកគ្រូ ។

ដាតា : តែគេលើកពីខាងផ្សេងម៉ោ?

សួប : ចា៎ គេចាប់ផ្ដើមពីដុបអីណោះម៉ោ ពីដុបចាក់ម៉ោវង់ទៅចេះម៉ោ ទៅចេះៗទៀត ។ សុតតែវាលស្រែលោកគ្រូអើយសុតតែដើមឈើ ។

ដារ៉ា : អញ្ចឹងពេលដែលមុខសញ្ញាដែលមីងលើកហ្នឹងភូមិប៉ោយតាអុង?

សួប : ភូមិប៉ោយតាអុង ។

ដារ៉ា : ដែលមីងទៅដល់មុនដំបូងអត់ទាន់មានទំនប់ជាអីទេ?

សួប : អត់ទាន់មានទំនប់ទេលោកគ្រូអើយវាលស្រែឡើយ ។

ដារ៉ា : មានគ្នាច្រើនទេទៅលើកនៅកន្លែងមុខសញ្ញាហ្នឹង?

សួប : ច្រើនតើលោកគ្រូអើយអ្នកថ្មីផង កាលហ្នុងគេជម្លៀសអ្នកថ្មីគៀនៗម៉ោផង ដល់ហើយជួបជុំគ្នាលើក យុវជន នារី កុមារកុមារីជុំគ្នា ។

ដារ៉ា : ចឹងការហូបចុកពេលណឹងម៉េចដែរកាលទៅដល់ដំបូង?

សួប : ហ៊ឺ! ..... ណាស់លោកគ្រូអើយមិនដែលពេញក្រពះទេ មួយកូនចានចង្កឹះចែកគ្នាម៉ាពេល សុតតែវាល់ចានចង្កឹះណាលោកគ្រូ វាល់ចានវាល់សម្ល សម្លបានមួយវែក បេះអន្លក់បេះអីគេថែមទៀត ចាក់ទឹកចាក់អី បើមិនថែមវាមិនឆ្អែត ដំបាយដែលគេបើកម៉ោនាំគ្នាបេះស្លឹកបះបេះស្លឹកអីទៅលាយ ដាក់ដំឲ្យបានច្រើនធ្វើម៉េចឲ្យបានឆ្អែតណាលោកគ្រូ ។

ដារ៉ា : ដាក់ដេះ?

សួប : ដំ ។

ដារ៉ា : ដំហ្នឹងស្អីគេ?

សួប : ដំយើងដាក់អង្ករ ដាក់បាយឲ្យគេបើក ជួនកាលលោកគ្រូដាក់បាយ ជួនកាលដាក់ស្លឹកឈើ ជួនកាលថែមទឹកថែមអីទៀត ដូចយើងបបរ ។

ដារ៉ា : យើងបបរឲ្យវាបានច្រើន?

សួប : ចា៎ ធ្វើម៉េចឲ្យវាបានឆ្អែត ។

ដារ៉ា : ចុះកាល អាម៉ោងពេលដែលយើងធ្វើការចាប់ផ្ដើមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

សួប : ចាប់ផ្ដើមពីម៉ោ៦ ។

ដារ៉ា : ៦ព្រឹកអ្ហេះ?

សួប : ចា៎ ម៉ោង៦ដល់ម៉ោង១២ ម៉ោង១ចុះធ្វើការវិញ ។

ដារ៉ា ៖ ដល់ម៉ោងប៉ុន្មានទៅ?

សួប ៖ ដល់ម៉ោង៥ ។

ដារ៉ា ៖ ដល់ម៉ោង៥ សម្រាកតែម្តងឬក៏ចុះធ្វើការតទៀត?

សួប ៖ សម្រាកលោកគ្រូ ដល់ពេលហូបបាយហើយចាប់ផ្តើមធ្វើយប់ទៀត ។

ដារ៉ា ៖ ធ្វើយប់ទៀត?

សួប ៖ ចាំ ចូលម៉ោង៧ ម៉ោង៧ដល់ម៉ោង៩ ។ លោកគ្រូនែ៎ និយាយឲ្យដល់ទៅស្រេចតែយើងរួច ២ម៉ែត្រគីបណាលោកគ្រូ មិនថាយប់ថាថ្ងៃទេកំណត់តែម៉ាររួច ។

ដាតា ៖ ៥ម៉ែត្រគីបឬ២ម៉ែត្រគីប?

សួប ៖ ២ម៉ែត្រគីប ២ម៉ែត្រកន្លះលោកគ្រូ ថ្ងៃ២ម៉ែត្រកន្លះយប់២ម៉ែត្រកន្លះ ។

ដារ៉ា ៖ ក្នុងម៉ាថ្ងៃហ្នឹងគឺជីងតែ៥ម៉ែត្រគីបឲ្យហើយ?

សួប ៖ ចាំ ម៉ាយប់ម៉ាថ្ងៃហ្នឹងជីងតែ៥ម៉ែត្រគីប ។

ដារ៉ា ៖ មីងលើកហើយដែរ?

សួប ៖ ចាំ លើកមិនហើយក៏ត្រូវគេហើយដែរបើគេបន្ទុំ គេដើរមើល ។

ដារ៉ា ៖ មីងថាប្រធានកងមីងឈ្មោះ ខៀន ហ្នឹងត្រូវជាសាច់ញាតិរបស់មីងដែរ?

សួប ៖ ចាំ បងប្អូន ។

ដារ៉ា ៖ បងប្អូន អញ្ចឹងគាត់មានការរឹតត្បិតអីទេជាមួយមីង?

សួប ៖ គាត់មិនបានទេនេះទេ គាត់ស្លូតណាស់គាត់ហ្នឹង ។ បានប្រធានធំៗគេកាច បានគាត់ប្រធានកងគាត់ក្តាប់ក្រោមណោះគាត់ស្លូត ។

ដារ៉ា ៖ ចុះការរស់នៅអីម៉េចវិញហ្នឹង?

សួប ៖ រស់នៅស្រួលទេគេធ្វើគ្រែឲ្យដេក គេធ្វើខ្ទមឲ្យ ។

ដារ៉ា ៖ មានប្រក់មានអីត្រឹមត្រូវទេ?

សួប ៖ ចាំ

ដារ៉ា ៖ យកអីប្រក់?

សួប ៖ កាលណោះសំពត់កៅស៊ូលោកគ្រូ ។

ដារ៉ា ៖ ចឹងពេលភ្លៀងពេលអីមានលិចទេ?

សួប ៖ ទេគ្មានលិចទេ ។

ដារ៉ា ៖ គ្មានលិចទេណោះ ។ ហើយចុះអារឿងទឹកផឹកអីនោះមីងសំបូរបែបទេ?

សួប ៖ ទឹកដឹកគេដឹកឲ្យ ។

ដារ៉ា ៖ គេដឹកឲ្យ?

សួប ៖ ចា៎ គេដឹកឲ្យដឹក ។

ដារ៉ា ៖ ហើយគេចែកជារបបជាអីម៉េចមីង?

សួប ៖ ចែកម៉ាក្រុមៗ កុមារាផ្សេង កុមារីផ្សេង យុវជនផ្សេង នារីផ្សេង ម៉ាប៉ាក់ៗ ។

ដារ៉ា ៖ ម៉ាប៉ាក់ៗ?

សួប ៖ ចា៎

ដារ៉ា ៖ ហើយមានគេម៉ោវាស់វែងអីទេនៅកន្លែងហ្នឹង កន្លែងត្រពាំងថ្មហ្នឹង?

សួប ៖ ជាប្រធានធំគេម៉ោពីខាងណាទេខ្ញុំអត់ស្គាល់គេ ពេលគេវាស់គេអីគេបើកឡានម៉ោ ធំជាងពុកវ៉ាល់ហ្នឹងទៀត ។

ដារ៉ា ៖ ធំជាងពុកវ៉ាល់?

សួប ៖ ចា៎

ដារ៉ា ៖ ហើយកាលមុនហៅពុកវ៉ាល់ៗហ្នឹងហេតុអីបានហៅអញ្ចឹង?

សួប ៖ ហៅពុកខ្លាចអំណាចគេចេះតែហៅទៅលោកគ្រូអើយ ហៅពុកហៅម៉ែ ដល់ពុកម៉ែរបូតហើយ កាលហ្នុង ។

ដារ៉ា ៖ ឲ្យតែអ្នកធំៗចឹងហៅពុកហៅម៉ែហើយណោះ?

សួប ៖ ចា៎

ដារ៉ា ៖ ហើយនៅក្នុងកងមីងចឹងមានបាត់មនុស្សបាត់អីទេ?

សួប ៖ បាត់លោកគ្រូអើយស្លាប់ ឈឺស្លាប់ផង ពេលទឹកឡើងម៉ោចេះ បើថាពេលដែលលើកទំនប់ខាងហើយ មានអីឃើញក្តាមរសាត់ម៉ោចេះចុះទៅលោតឃើញក្តាមរត់ទៅចាប់ធ្លាក់ចូលទៅក្នុងអាងស្លាប់ ។

ដារ៉ា ៖ មានធ្លាក់ចូលក្នុងអាងដែរ?

សួប ៖ ចា៎ ធ្លាក់ចូលណាលោកគ្រូអើយស្ដាយស្លាប់ណាស់ ដែលដើងកប់ទាញ ដល់លើកខាងៗទោមានដើងកប ស្លាប់ច្រើនតែអ្នកថ្មី ។

ដារ៉ា ៖ អ្នកថ្មីច្រើនមកពីខាងណា?

សួប ៖ ជម្លៀសម៉ោយើងម៉ោពីខាងចិនខាងអីទៅណាលោកគ្រូ ម៉ោពីឆ្ងាយៗកំពង់ចាម កំពង់ឆ្នាំងអីតាកែវ ព្រៃវែងអីណាលោកគ្រូ ។

ដារ៉ា : ម៉ោនៅហ្នឹង?

សួប : ចាំ ដែលគេជម្លៀសម៉ោនោះណាលោកគ្រូ គេជុំគ្នា ប្រមូលគ្នាទៅលើម្តុំទៅ ។

ដារ៉ា : ចុះមានការចាប់យកទៅសម្លាប់ដែរទេ?

សួប : មានលោកគ្រូពួកខ្ញុំកំពុងប្រជុំចេះ ដូចថាជិតយួនចេះគេមានទុកណា ហើយកូនចៅរញ៉េករញ៉ាក ហើយកំពុងប្រជុំចេះគេយកទៅវ៉ៃចោល ដល់ពេលនេះកូនយំរញ៉ូ ដល់ពេលនេះគេលីចបកាប់ទៅ ដល់ពេលនេះវ៉ៃម៉ែវ៉ៃឪទៅ កូនយំរញ៉ូ ពួកខ្ញុំភ័យអើយញ័រអស់ ។

ដារ៉ា : អ្នកដែលគេយកទៅវ៉ៃហ្នឹងគាត់ធ្វើអីខុស មានកំហុសអី?

សួប : លោកគ្រូកាលណោះណា ឲ្យតែជិតយួនអត់ទុកទេណាជិតយួន ។

ដារ៉ា : មីងស្គាល់អ្នកដែលគេយកទៅសម្លាប់ហ្នុងទេ?

សួប : មិនបានស្គាល់ទេកាលនោះមិនសូវចាំផងខ្ញុំនៅតូចៗ ។

ដារ៉ា : ជាប្រុសស្រី?

សួប : កាលណោះប្រុសផងស្រីផងគេអំណាច ដល់នេះប្រធានគេម៉ោពីឆ្ងាយៗកាលនោះខ្ញុំមិនសូវស្គាល់គេច្បាស់ផងខ្លាចគេនៅតូចផង ។

ដារ៉ា : អ្នកដែលគេយកទៅសម្លាប់ដែលគេចោទថាយួនហ្នឹងមីងអាចស្គាល់ឈ្មោះគេទេ?

សួប : ខ្ញុំអត់ស្គាល់ទេដឹងតែនីរតី ។

ដារ៉ា : អត់ទេៗអ្នកដែលស្លាប់ដែលគេចោទថាយួនហ្នឹងអ្ហាស?

សួប : អត់ស្គាល់ទេលោកគ្រូ ។

ដារ៉ា : ដែលគេចោទថាយួនហ្នឹងអ្ហាស គាត់យួនមែនឬក៏យ៉ាងម៉េច?

សួប : មិនដឹងទេខ្ញុំអត់ស្គាល់ទេប៉ុន្តែនឹងភូមិ ភូមិខ្ញុំទៅធ្វើការដែលគេយកទៅ ពួកខ្ញុំនៅនឹងភូមិហ្នឹង ដល់ឃើញគេ ។

ដារ៉ា : ឃើញគេថាម៉េចទៅ?

សួប : ឃើញគេទៅគេយកទៅរៀន និយាយអីលោកគ្រូឃើញគេបណ្តើយកទៅវ៉ៃនៅកើត ឃើញគេទៅខ្លាចមិនហ៊ាននិយាយអីទេខ្លាចគេយកទៅវ៉ៃចោល ។

ដារ៉ា : ហើយមីងថាអ្នកដែលគេបណ្តើរយកទៅវ៉ៃចោលហ្នឹងជាយួន?

សួប : ទេកាលពីសម័យអាពតឲ្យតែយួនគេយកទៅវ៉ៃចោលលោកគ្រូ ហើយបងប្អូនដែលធ្វើធំធ្វើតូចអីជាប់ និយាយខ្ញុំបងប្អូនធ្វើទាហានម្នាក់ខ្ញុំភ័យឡើងញ័រអស់ខ្លាចគេយកទៅវ៉ៃចោល ។

ដារ៉ា : ហើយចុងក្រោយគេយកទៅមែនឬក៏អត់?

សួប ៖ ទេបេះតែនៅៗទៅ ខ្ញុំបេះតែលួងៗប្រធានក្រុម លួងថាបងអើយប្រហែលគេយកខ្ញុំទៅវ៉ៃចោលខ្ញុំខ្លាច ហើយបេះតែភ័យបេះតែសុំគេ ។

ជាតា ៖ ហើយចុះអ្នកដែលធ្វើទាហាននោះបងប្អូនមីងហ្នឹងគាត់ទៅណាទេ?

សួប ៖ គាត់ស្លាប់ហើយស្លាប់កាលអាពត ។

ជាតា ៖ គេយកទៅ?

សួប ៖ ឲ្យតែជាប់ទាហានអត់ហ៊ានទៅទេវត់ទៅកើត ដឹងថាគេចាប់បានដឹងថាអីទេ ចុះបាត់ខ្លួនដល់សព្វថ្ងៃ ។ ដឹងថាងាប់ដោយសារគេវ៉ៃបាន ដឹងថាងាប់គេចាក់សាំងដុតដែលគេល្បីម៉ាសារគេចាប់បានគេយកទៅដាក់ទ្រុងជ្រូកទៅគេចាក់សាំងដុត ឮសព្វថ្ងៃ ។

ដារ៉ា ៖ ចុះមាន ថានៅម្ដុំហ្នឹងថាពេលខែភ្លៀងខែអីមានរុយមានអី ថាគគ្រេចណាស់ណាមីង?

សួប ៖ មានរុយលោកគ្រូ លោកគ្រូអើយកន្លែងដាំបាយកន្លែងណាក៏ឡើងល្វិតឈឹង កាលនោះអត់មានអនាម័យទេណាលោកគ្រូអត់មានអនាម័យទេ អ្នកណាធ្វើអីស៊ីក៏ទុកចោលបណ្ដោយបណ្ដោ ។

ដារ៉ា ៖ ចុះមិនមានឈឺថ្កាត់អីច្រើន?

សួប ៖ ឈឺលោកគ្រូអើយឈឺគេយកទៅដេកពេទ្យនៅប៉ោយតាអុង អរ! នែ៎ៗស្លាប់តាខែត្រយើងនេះកន្លែងពេទ្យ ។

ដារ៉ា ៖ ស្លាប់តាខែត្រ?

សួប ៖ ចា៎ កន្លែងពេទ្យ ។

ដារ៉ា ៖ កន្លែងពេទ្យគេហ្នឹង?

សួប ៖ ចា៎

ដារ៉ា ៖ ភាគច្រើនឈឺអីគេទៅកាលហ្នុង?

សួប ៖ ឈឺជម្ងឺស៊ីបាយមិនឆ្អែតណាលោកគ្រូ ធ្វើការជាប់ជុនៗដល់ឈឺគ្រុនដំបៅជើងដំបៅដៃអីទៅ ។

ដារ៉ា ៖ មានស្លាប់ដោយជម្ងឺដែរទេ?

សួប ៖ ចា៎ ស្លាប់ដោយជម្ងឺច្រើនលោកគ្រូ ហើយដាច់ពោះ ។

ដារ៉ា ៖ ចុះមីងលើកនៅហ្នឹងលើកនៅកងជាមួយ ខៀន ហ្នឹងរហូតម៉ោ?

សួប ៖ ចា៎

ដារ៉ា ៖ ដល់ពេលណាទៅ?

សួប ៖ ដល់ពេលយួនចូល ដល់សម្រេចម៉ោនីងៗលើត្រគៀបក្ដាមនេះ គេដឹកឲ្យពួក ឲ្យពួកខ្ញុំដឹកស្រះ ៣, ៣អី៤ ដឹក៤គេថាបម្រុងជប់លាងនុំបញ្ចុកគេប្រុងបោកគ្រាប់បែកហ្នឹងឯង ប្រុងសម្លាប់

សំណាងនឹងចៃដន្យយួនចូលម៉ោ រថក្រោះម៉ោបាញ់ភឹងភឹងៗប្រធានក៏រត់ចេញអស់ ពួកខ្ញុំក៏ឡើងចេញពីក្នុងស្រះ ហ្វី! ប្រធានទៅណាអស់អញ្ចេះ តោះពួកយើងទៅផ្ទះ នាំគ្នាម៉ោផ្ទះ ។

ដារ៉ា : អរ! កាលដែលជីកស្រះជីកអីហ្នឹងជីកសម្រាប់អី?

សួប : ជីកសម្រាប់ពួកខ្ញុំងាប់នឹងឯង ។

ដាតា : អរ! គេឲ្យយើងជីកខ្លួនឯង?

សួប : ជីកខ្លួនឯងគេប្រុងជប់លៀងនុំបញ្ចុក ថ្ងៃណោះដូចជាចៃដន្យអាយុវែង អាយុមិនទាន់អស់ចេះតែនៅបានយូរម៉ោដល់សព្វថ្ងៃ ។

ដារ៉ា : ខ្ញុំចង់សួរបញ្ជាក់កន្លែងហ្នឹង គឺថាពួកខ្មែរក្រហមឲ្យជីកស្រះហ្នឹងដោយខ្លួនឯង រួចហើយគេប្រុងជប់លៀងឲ្យហូបនុំបញ្ចុក អញ្ចឹងអ្ហេះ?

សួប : ចា៎ ប្រុងអីលោកគ្រូជប់លៀងហើយ យុវជនស្រះមួយ នារីស្រះមួយ កុមារាស្រះមួយ កុមារីស្រះមួយ ប៉ុនតែគ្នាចូលទៅហូបក្នុងស្រះហើយណា ។

ដារ៉ា : អ្ហាក! នុំបញ្ចុកហ្នឹងប្រុងចូលទៅហូបក្នុងស្រះ?

សួប : ហូបហើយលោកគ្រូចូលហូបក្នុងស្រះហើយ ។

ដារ៉ា : ហូបក្នុងស្រះហ្នឹង?

សួប : ចា៎ លោកគ្រូអង្គុយហូបហើយអីហើយ ក៏រួចក៏នាំគ្នាចេញម៉ោដឹកទឹក ប្រធានប្រពន្ធសេរ៉ូមួយស្រែកថា បើហូបរួចហើយដឹកទឹករួចហើយចុះទៅក្នុងស្រះវិញប្រជុំ ថាអញ្ចេះ ។ ហើយពួកខ្ញុំក៏ចុះទៅហើយ ចុះទៅមិនទាន់អស់ទេ ដល់ម៉ាសន្ទុះទៅក៏ព្រួយួនចូលម៉ោរំដោះ ។

ដារ៉ា : ចុះប្រុងម៉េច ប្រុងចូលទៅប្រជុំក្នុងស្រះហ្នឹងប្រុងគប់គ្រាប់បែកសម្លាប់ទាំងអស់ប្ញុក៏យ៉ាងម៉េច?

សួប : ចា៎ គេប្រុងធ្វើបាបធ្វើបាបណាលោកគ្រូ ។

ដារ៉ា : ម៉េចបានមីងដឹង?

សួប : ព្រុតែគេនិយាយ មានទីរសារ ប្រធានៗគេរត់អស់ទៅនៅទីរសារគេថា សំណាងហើយកុំអីងាប់ ស្រះទាំងពីរទាំងបីកុំអីពួកយើងងាប់ ។

ដារ៉ា : អញ្ចឹង!

សួប : ចា៎

ដារ៉ា : ចុះហ្នឹង ពេលហ្នឹងឈ្មោះ ខៀន ហ្នឹងដែលជាប្រធានកងអត់ដឹងទេមីង?

សួប : អត់ដឹងទេ ស្រេចតែគេម៉ោពីលើម៉ោ យើងប្រធានកងល្មមៗអត់ដឹងទេ ។

ជាតា  :  ចុះគាត់ក៏ស្លាប់ដែរបើសិនជាគេសម្លាប់អ្នាស?

សួប  :  បើសិនជាគេសម្លាប់គាត់ក៏ស្លាប់ដែរ ។

ដារ៉ា  :  ដល់ចឹងពេលហ្នឹងក៏រត់ម៉ោផ្ទះម៉ោមីងណោះ?

សួប  :  ចា៎  ម៉ោផ្ទះនាំគ្នារត់ម៉ោផ្ទះលោកគ្រូអ្ហើយនាំគ្នារត់ម៉ោផ្ទះ ។

ដារ៉ា  :  អាពេលឲ្យដឹកហ្នឹងពួកណាពួកនីរតីឬក៏ពួកណាមីង ?

សួប  :  នីរតី  ជើងខោវាធំៗ ។

ដារ៉ា  :  ជើងខោងធំៗ?

សួប  :  ចា៎  អ្ហើយលោកគ្រូអ្ហើយជើងខោវាប៉ិនៗណោះ ។

ដារ៉ា  :  កាចទេមីងពួកហ្នឹង?

សួប  :  កាចណាស់លោកគ្រូអ្ហើយនិយាយពីកាច ។

ដារ៉ា  :  បើធៀបជាមួយតាវ៉ាល់ខុសគ្នាម៉េចដែរ?

សួប  :  ខុសគ្នាឆ្ងាយណាស់   ពុកវ៉ាល់គាត់ស្លូតគាត់ល្អណាស់ ។   នីរតីម៉ោក្លាមកាច   សម្លាប់ប្រធានៗ ពួកតាវ៉ាល់ពួកអីចោលអស់  គេកាន់អំណាច ។

ដារ៉ា  :  ចឹងពេលវៀតណាមចូលម៉ោមីងម៉ោដល់ភូមិវិញទៅ?

សួប  :  ចា៎  ម៉ោដល់ភូមិវិញជួបម៉ែជួបឪវិញ  បាត់ឪពុកស្លាប់អត់តាំងជួបផង  សុំគេម៉ោគេមិនតាំងឲ្យ ម៉ោផង ។

ដារ៉ា  :  កាលហ្នឹងមីងដឹងដែរតើដែលថាឪពុកស្លាប់?

សួប  :  ចា៎  ដឹងហើយលោកគ្រូ  តែគេឲ្យទៅលើកដីលើកអី  អាយុ១០ជាងហើយ ។

ដារ៉ា  :  ដល់ពេលដឹងដំណឹងមានសុំម៉ោ?

សួប  :  សុំគេអត់ឲ្យម៉ោ ។

ដារ៉ា  :  គេថាម៉េចទៅ  សុំអ្នកណា?

សួប  :  សុំប្រធានគេ ។

ដារ៉ា  :  ប្រធានហ្នឹងមិន  ខៀន?

សួប  :  ទេអឹំ  ខៀន  ឲ្យម៉ោ  ប៉ុន្តែប្រធានធំលើអឹំ  ខៀន  ទៀតគេអត់ឲ្យម៉ោ ។

ដារ៉ា  :  អ្នកណាគេលើគាត់?

សួប  :  នីរតីហ្នឹងឯងគេចូលម៉ោ ។

ដារ៉ា  :  អត់មានដែលស្គាល់ឈ្មោះមួយទេណោះខាងនីរតី?

សួប ៖ អត់ស្គាល់ទេលោកគ្រូអើយ ។

ដារ៉ា ៖ ហើយមីងក្រោយម៉ោហ្នឹងមីងមានដែលនិយាយរឿងរ៉ាវហ្នឹងប្រាប់កូនចៅមីងទេ?

សួប ៖ និយាយៗប្រាប់កូនថា នាងអ្ហើយសំណាងហើយម៉ែមិនងាប់ បើសិនជាម៉ែងាប់មិនដឹងជាកូនឯងទៅកើតអីណា មិនដឹងទៅរកម៉ែអីណានឹងហៅទេ ចេះតែនិយាយរឿងប្រាប់កូនទៅណា ។

ដារ៉ា ៖ រឿងអីខ្លះដែលមីងចំណាំនិយាយប្រាប់កូន?

សួប ៖ ប្រើកូនមិនបានទៀត វាពោលថា ពេលធ្វើម្ហូបឲ្យវាហូបវារើសរូសមិនព្រមហូប វាថាម៉ែឯងមិព្រមធ្វើអានេះអានោះហូបទេហូបបាយទទេ ហ្អឺ! កូនអ្ហើយបានបាយទទេហូបគ្រាន់ហើយ កាលម៉ែគេវាល់បបរវាល់បាយចែកគ្នា តែម៉ែបុណ្យថាឲ្យធ្វើម៉េចបានសន្តិភាពសុស្រួលទៅ បាយទទេក៏ម៉ែហូប ម៉ែបុណ្យថាចេះ កូនឯងបានប៉ិនណេះហើយកូនឯងរើសរក ស្អីក៏ហូបៗទៅកូន កាលពីម៉ែល្ហេមល្ហាមទៅដេកតាមស្រុកតាមព្រៃ សម័យកូនឯងស្រួលហើយ ។

ដារ៉ា ៖ ហើយកូនថាម៉េចទៅមីង?

សួប ៖ កូនថា ហ្អឺ! ខ្ញុំចង់ធ្វើអាម៉ាកនោះឯង (សើច)

ដារ៉ា ៖ ទៅអញ្ចឹងវិញ?

សួប ៖ ដល់នេះទៅនិយាយទៅនិយាយម៉ោ វាថាកាលសម័យម៉ែឯង សម័យខ្ញុំស្រួលចង់ងាប់ចង់រាំៗ ចង់ទៅបាងកកៗ ចង់នៅផ្ទះៗស្រួលចង់ងាប់ សម័យម៉ែឯងនៅផ្ទះមិនបានទេ នៅជួបជុំម៉ែឪមិនបានទេ ។ មែនណាលោកគ្រូនៅជួបជុំមិនបានទេ ហ៊ានតែម៉ោលេងម៉ាថ្ងៃដឹងតែម៉ាថ្ងៃ តែហួសតែពីរថ្ងៃ ម៉ាថ្ងៃមិនឃើញទៅពីរថ្ងៃលោកគ្រូអ្ហើយចាប់ចងបង្អត់បាយពីរយប់ពីរថ្ងៃ ឲ្យឈរជើងមួយទៀត ហាលមូសហាលភ្លៀង មិនលេងទេលោកគ្រូអ្ហើយ ខ្ញុំបុណ្យឲ្យតែស្រុកសន្តិភាព ។

ដារ៉ា ៖ មីងខ្ញុំចង់សួរបញ្ជាក់តិច កន្លែងដែលមីងរត់ម៉ោពីត្រពាំងថ្មហ្នឹងគេថាមានកន្លែងជីកស្រះឲ្យហូបនុំបញ្ចុកអីហ្នឹងមីង អាហ្នឹងនៅភូមិអីមីង?

សួប ៖ នៅភូមិវាលត្រកៀបក្តាមយើង វាលស្រែ ។

ដារ៉ា ៖ នៅវាលស្រែម៉ង?

សួប ៖ ចា៎ៗ ប៉ុនតែហៅវាលត្រកៀបក្តាម ។

ដារ៉ា ៖ វាលត្រកៀបក្តាម?

សួប ៖ ចា៎

ដាតា ៖ ពេលហ្នឹងនៅក្នុងត្រពាំងថ្មដដែលឬក៏?

សួប ៖ ទេនៅខាងណោះទេ ។

ជាតា ៖ ភូមិត្រពាំងថ្មដែរ?

សួប ៖ ចា៎ ខាងកើតយើង ខាងកើតវត្តព្រះនេត្រព្រះចំលោកគ្រូ ។

ដារ៉ា ៖ អរ! បាទ

សួប ៖ នៅខាងត្បូងរហាល ។

ដារ៉ា ៖ ចុះម៉េចៗ មានគំនិតអីបានជាចង់ទៅសម្លាប់កងកុមារ កងយុវជនកងអីវិញចឹង ព្រោះក្រែង (ឆ្លើយកាត់)

សួប ៖ ព្រោះគេចង់ឡើងសោយរាជ្យណា គេចង់យកតំបន់យើងនេះណា គេធ្វើម៉េចឲ្យ គេចង់ម៉ោនៅស្រុកស្រែខ្មែរយើងអីណោះ ។

ដារ៉ា ៖ បើអ្នកទាំងអស់ហ្នឹង ដូចកងកុមារកងអីជាអ្នក ជាកងដូចថាកម្លាំងអ្នាស លើកដី ប្រូតអី ភ្ជួរអី ហេតុអីបានសម្លាប់ពួកហ្នឹងអស់បានអី?

ជាតា ៖បានពីណាធ្វើទៀត?

សួប ៖ គេយកគ្នាគេម៉ោតតាំង ឲ្យពួកយើងងាប់អស់ទៅក៏គេយកគ្នាគេម៉ោនៅទៅ ។

ដារ៉ា ៖ មីងចង់សំដៅថាពួកនិរតីហ្នឹងអ្ហេះ?

សួប ៖ ចា៎

ដារ៉ា ៖ យកពួកនិរតីគ្នាគេហ្នឹងម៉ោនៅ?

សួប ៖ ចា៎ៗ ចុះត្រូវសម្លាប់ពួកយើងនេះអ្នាស សំណាងអាយុមិនទាន់អស់កុំអីអ្ហើយមិនបានឃើញស្រុកស្រែស្រួលដូចសព្វថ្ងៃទេលោកគ្រូអើយ ខ្ញុំចង់បានតែប៉ុនណោះមិនចង់ឲ្យកើតអាសម័យចាស់ៗទៀតទេ ។

ដារ៉ា ៖ ចឹងមីងគិតថាមានគំនិតយ៉ាងម៉េចដែរ ធ្វើយ៉ាងណាដើម្បីកុំឲ្យរបបប៉ុល ពតហ្នឹងវិលត្រឡប់មកម្តងទៀត?

សួប ៖ ខ្ញុំចង់ឲ្យនៅតែចេះ ខ្ញុំបោះឆ្នោតខ្ញុំបោះយកតែឪយើងសព្វថ្ងៃនេះទេ ខ្ញុំបានចូលខ្ញុំភ្លេចគុណគាត់ទេ ។ និយាយកាលណាខ្ញុំចង់តែទឹកភ្នែក ។

ដារ៉ា ៖ យើងវាកំសត់វាឈឺចាប់ ។

សួប ៖ ចា៎

ដារ៉ា ៖ ចុះនៅក្នុងភូមិមីងនេះកាលពីសម័យប៉ុល ពតចូលម៉ោមានកន្លែងណា មីងមានស្គាល់កន្លែងណាដែលជាកន្លែងសន្តិសុខរបស់ភូមិរបស់ឃុំអីទេនៅក្នុងភូមិមីង?

សួប ៖ កាលណោះខ្ញុំអត់ស្គាល់ទេ គេឲ្យទៅត្រង់ណោះក៏ទៅឲ្យទៅត្រង់ណោះក៏ទៅៗ អាកន្លែងទីតាំងប្រធានគេដឹងនៅត្រង់ណាត្រង់ណីទេ ។

ដារ៉ា ៖ អញ្ចឹងពួកខ្ញុំដូចជាអត់មានសំនួរអីទៀតទេមីង ។

សួប ៖ ចា៎ៗ

ដារ៉ា ៖ ហើយពួកខ្ញុំអរគុណច្រើនដែលបានផ្តល់បទសម្ភាសន៍មីងណាស់ ។

សួប ៖ ខ្ញុំយ៉ាងណាៗមិនភ្លេចឪយើងសព្វថ្ងៃទេឪយើងសព្វថ្ងៃ ។

ដារ៉ា ៖ អរគុណច្រើនមីងណាស់ ។

សួប ៖ ចា៎ៗ

«ចប់»